**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ស្ថាប័ន ក្រសួង រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៦ :** អនុក្រឹត្យនេះមានអានុភាពអនុវត្តិ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៤*

# អនុក្រឹត្យលេខ ១៣ អនក្រ
# ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**មាត្រា ១ :** ត្រូវបានបង្កើត ក្រុមប្រឹក្សាអ្នកច្បាប់ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **សុខ អាន** | រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | ជាសហប្រធាន |
| ២-ឯកឧត្តម **ម៉ៅ សិរីវុឌ្ឍ** | រដ្ឋមន្ត្រីទីស្តីគណៈរដ្ឋមន្ត្រី | ជាសហប្រធាន |
| ៣-ឯកឧត្តម **សាយ បូរី** | រដ្ឋលេខាធិការទំនាក់ទំនងជាមួយសភា | អនុប្រធាន |
| ៤-ឯកឧត្តម **ហោ ចន្ទប៊ុននាក** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ | អនុប្រធាន |
| ៥-ឯកឧត្តម **អ៊ុក ទិធុន** | ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ | សមាជិក |

៧_ឯកឧត្តម គង់ ភិរុន ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ សមាជិក

៨_លោក សៅ ម៉ុនហុង ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៩_លោក ចន្ទ តានី ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១០_លោក ហែម ក្រាញ់ភូនី ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**មាត្រា ២ :** ក្រុមប្រឹក្សាអ្នកច្បាប់មានភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីលើកគំរោងកសាងច្បាប់ ឬ លិខិតបទដ្ឋានថ្មីៗ ដែលមានការចាំបាច់សំរាប់បំរើអោយសកម្មភាពរាជរដ្ឋាភិបាល ។

-សិក្សា និងតាមដាន អត្ថបទច្បាប់ និងលិខិតបទដ្ឋានទាំងឡាយដែលត្រូវបានប្រកាសចេញអោយប្រើ ដែលលែងសមស្រប នឹងសភាពការណ៍ជាក់ស្តែងដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលធ្វើវិសោធនកម្ម ។

-សិក្សា និង ផ្តល់យោបល់ជូនគណៈរដ្ឋមន្ត្រីអំពីសេចក្តីព្រាងច្បាប់លិខិតបទដ្ឋាន សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយជាមួយអន្តរជាតិ ដែលបណ្តាក្រសួងស្ថាប័ន ផ្ញើរមកសុំសេចក្តីអនុម័តពីគណៈរដ្ឋមន្ត្រី ។

-ចាត់ចែងធ្វើសេចក្តីព្រាងច្បាប់ ឬ លិខិតបទដ្ឋាននៅជូនស្ថាប័នដែលមានសមត្ថកិច្ចផ្តល់សច្ចាប័នជាចុងក្រោយអោយបានសមស្របតាមនីតិវិធី ។

**មាត្រា ៣ :** ក្រុមប្រឹក្សាអ្នកច្បាប់ មានក្រុមជំនាញមួយជាជំនួយការដែលមានសមាសភាពដូចខាងក្រោម :

១_លោក ឡេង ម៉េងឡុង ជាប្រធាន

២_លោក ឌូ បេន ជាអនុប្រធាន

៣_លោក គួច ចណ្ណលី ជាអនុប្រធាន

៤_លោក ឌី សូភីន សមាជិក

៥_លោក សៅ គឹមសរ សមាជិក

៦_លោក អ៊ុក សារី សមាជិក

៧_លោក គង់ ហេង សមាជិក

**មាត្រា ៤ :** សមាជិកទាំងអស់ ព្រមទាំងក្រុមជំនួយការរបស់ក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តមអស់លោក ដែលមាននាមក្នុងមាត្រា ១ និង មាត្រា ៣ មានភារកិច្ចអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ១៤ អនក្រ
## ស្តីពីការបែងចែកខ្ទង់ចំណាយឥណទានទុក

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ